# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. 0៤៧ MOC / SM 2013

# ប្រកាស
## ស្តីពី
## ការកំណត់តម្លៃចារឹកលើប័ណ្ណភាគហ៊ុន តាមការអនុវត្តមាត្រា ១៤៣ និង ១៤៤ នៃច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម
-បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
-បានឃើញប្រកាសលេខ ២០៩ MOC/SM២០០៧ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់នាយកដ្ឋាននីតិកម្ម
-បានឃើញប្រកាសលេខ ២០៨ MOC/SM២០០៧ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម
-យោងតាមការចាំបាច់ របស់ក្រសួងពាណិជ្ជកម្ម

## <u>សម្រេច</u>

### <u>ប្រការ ១</u>.- គោលបំណង

ប្រកាសនេះ មានគោលបំណងសម្រួលដល់ការកំណត់តម្លៃចារឹកលើប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនដែលធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈ តាមការអនុវត្តមាត្រា ១៤៣ និងមាត្រា ១៤៤ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។

ក្រសួងពាណិជ្ជកម្ម
លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្ម (ផ្លូវ១១៣បេ)
ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៦៦ ០៨៨/៨៦៦ ៩៧៨
ទូរសារលេខ: (៨៥៥) ២៣ ៨៦៦ ៤២៥
អ៊ីម៉ែល: moccab@moc.gov.kh

**ប្រការ ២.- វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះតែក្រុមហ៊ុនដែលធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈប៉ុណ្ណោះ។

**ប្រការ ៣.- តម្លៃចារឹកលើប័ណ្ណភាគហ៊ុន**

ក្រុមហ៊ុនទាំងឡាយណាដែលធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈ ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិផ្សេងៗ អាចកំណត់ ឬកែប្រែនូវតម្លៃចារឹកលើប័ណ្ណភាគហ៊ុនតិចជាង ៤.០០០ (បួនពាន់) រៀល ក្នុងមួយហ៊ុនបាន។

ក្រុមហ៊ុនទាំងឡាយណាដែលមិនធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈ ពុំអាចកែប្រែតម្លៃចារឹកលើប័ណ្ណភាគហ៊ុន តិចជាង ៤.០០០ (បួនពាន់) រៀលក្នុងមួយហ៊ុនៗនោះទេ។

**ប្រការ ៤.- លក្ខខណ្ឌ**

ក្រុមហ៊ុនដែលធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈ និងក្រុមហ៊ុនដែលមានបំណងបោះផ្សាយលក់មូលបត្រជាសាធារណៈ ក្នុងតម្លៃចារឹកលើប័ណ្ណភាគហ៊ុនតិចជាង ៤.០០០ (បួនពាន់) រៀលក្នុងមួយហ៊ុន ត្រូវដាក់ពាក្យស្នើសុំមកក្រសួងពាណិជ្ជកម្ម ដើម្បីកែប្រែតម្លៃចារឹកលើប័ណ្ណភាគហ៊ុន របស់ក្រុមហ៊ុន តាមរយៈការកែប្រែលក្ខន្តិកៈក្រុមហ៊ុន។

**ប្រការ ៥.- អវសានបញ្ញត្តិ**

ប្រកាស និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៦.-**

នាយិកាខុទ្ទកាល័យ អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គាធិការដ្ឋាន នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នាយកដ្ឋាននីតិកម្ម នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ មានភារកិច្ចអនុវត្តសេចក្តីប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៣

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**ចម្លងជូន:**

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ ម៉ែន សំអន
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី គាត ឈន់
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ
- គណៈកម្មការមូលបត្រកម្ពុជា
- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- ដូចប្រការ៦
- ឯកសារ -កាលប្បវត្តិ

**ក្រសួងពាណិជ្ជកម្ម**
លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្ម (ផ្លូវ១១៣បេ)
ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៦៦ ០៨៨/៨៦៦ ៩៧៨
ទូរសារលេខ: (៨៥៥) ២៣ ៨៦៦ ៩២៨
អ៊ីម៉ែល: moccab@moc.gov.kh